# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៣៥ សសរ

# សេចក្តីសំរេច
## ស្តីពី
## ការបង្កើតគណៈកម្មការចំរុះអន្តរក្រសួង
## អង្កេតស្រាវជ្រាវ ករណីរណសិរ្សជាតិរំដោះកម្ពុជាក្រោម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## <u>សំរេច</u>

<u>ប្រការ១</u>: -

បង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីអង្កេតស្រាវជ្រាវករណីរណសិរ្សជាតិរំដោះកម្ពុជាក្រោម ដែលមានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម នាយឧត្តមសេនីយ៍ **ហុក ឡុងឌី** អគ្គស្នងការនគរបាលជាតិ **ប្រធាន**

២-ឯកឧត្តម ឧត្តមសេនីយ៍ឯក **មល រឿប** នាយរងសេនាធិការចំរុះ និងជាប្រធាននាយកដ្ឋានស្រាវជ្រាវចារកិច្ចយោធា **អនុប្រធាន**

៣-ឯកឧត្តម ឧត្តមសេនីយ៍ឯក **សៅ សុខា** មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស **សមាជិក**

៤-ឯកឧត្តម ឧត្តមសេនីយ៍ទោ **យូ ស៊ុនឡុង** ប្រធាននាយកដ្ឋានកណ្ដាលសន្តិសុខ **សមាជិក**

៥-ឯកឧត្តម ឧត្តមសេនីយ៍ទោ **សុខ ផល** ប្រធាននាយកដ្ឋានពត៌មានទូទៅ **សមាជិក**

៦-លោក ឧត្តមសេនីយ៍ត្រី **ជុម ហាក់** នាយរងសេនាធិការ និងជាប្រធានការិយាល័យទី២ នៃកងទ័ពជើងគោក **សមាជិក**

៧-លោក ឧត្តមសេនីយ៍ត្រី **ខាង គីមហោ** ប្រធាននាយកដ្ឋានគរបាលព្រហ្មទ័ណ្ឌ **សមាជិក**

**ប្រការ២:-**

គណៈកម្មការចំរុះអន្តរក្រសួងនេះមានភារកិច្ច :

-ពិនិត្យស្រាវជ្រាវអង្គការចាត់តាំងទាំងខាងនយោបាយ និងយោធារបស់រណសិរ្សជាតិរំដោះកម្ពុជាក្រោម ។

-ពិនិត្យស្រាវជ្រាវប្រមែប្រមូលឯកសារវត្ថុតាងផ្សេងៗ ដែលទាក់ទងដល់សកម្មភាពរណសិរ្សជាតិរំដោះកម្ពុជាក្រោម ។

-ទំនាក់ទំនងសហការជាមួយស្ថាប័នផ្សេងៗ និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីប្រមែប្រមូល ឯកសារដែលទាក់ទងដល់រណសិរ្សរំដោះកម្ពុជាក្រោម ។

-ក្រោយពីប្រមូលបានពត៌មានសព្វគ្រប់ គណៈកម្មការត្រូវប្រជុំវាយតម្លៃ រួចរាយការណ៍លទ្ធផលការងារ ជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី ដើម្បីរាយការណ៍បន្តជូនសម្ដេចនាយករដ្ឋមន្ត្រី ដើម្បីពិនិត្យនិងមានវិធានការតាមការជាក់ស្ដែង ។

**ប្រការ៣:-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គស្នងការនគរបាលជាតិ មេបញ្ជាការកងទ័ពជើងគោក និងសមាសភាពដូចចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្ដីសំរេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០០២

**ឧ.នាយករដ្ឋមន្ត្រី**

**ឧបនាយករដ្ឋមន្ត្រី**

**ស ខេង**

<u>កន្លែងទទួល</u>:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- ឯកសារ-កាលប្បវត្ត